**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...១២០...សហវ.-ប្រក

លិខិតចូល
ថ្ងៃទី១៨...ខែមីនា...ឆ្នាំ2008

# ប្រកាស

## ស្តីពីការកែសម្រួល

## ប្រកាសលេខ ២១៨សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើត គណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ២១៨សហវ.ប្រក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងលើភាពចាំបាច់របស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលប្រការ ១ នៃ ប្រកាសលេខ ៦៧៨សហវ.ប្រក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដូចខាងក្រោម ÷

**ប្រការ ១ ថ្មី.-**

បង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហៅកាត់ «គគហ» ដែលរួមមានសមាសភាពដូចខាងក្រោម ÷

***I. ថ្នាក់ដឹកនាំក្រសួង***

| | | |
|---|---|---|
| ១- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋលេខាធិការ កសហវ | ប្រធាន |

***II. ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន***

| | | |
|---|---|---|
| ២- ឯកឧត្តម **ហង់ ជួន ណារ៉ុន** | អគ្គលេខាធិការ កសហវ | អនុប្រធានប្រចាំការ |
| ៣- ឯកឧត្តម **ជុំ គឹមឡេង** | អគ្គលេខាធិការរង កសហវ | អនុប្រធាន |
| ៤- ឯកឧត្តម **ចន្ទី ទិស្សរ័ត** | អគ្គលេខាធិការរង កសហវ | សមាជិក |
| ៥- ឯកឧត្តម **ជុំ ទិជិត្ត** | អគ្គលេខាធិការរង កសហវ | សមាជិក |
| ៦- ឯកឧត្តម **ម៉ាន សាហ៊ីម** | អគ្គលេខាធិការរង កសហវ | សមាជិក |
| ៧- ឯកឧត្តម **ញឹម ខេមរា** | អគ្គលេខាធិការរង កសហវ | សមាជិក |

***III. ថ្នាក់ដឹកនាំនាយកដ្ឋាន***

| | | |
|---|---|---|
| ៨- ឯកឧត្តម **ម៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និង រដ្ឋាករ | សមាជិក |
| ៩- ឯកឧត្តម **ទិន យន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ | សមាជិក |
| ១០- លោក **ឆួច ឡេង** | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច | សមាជិក |
| ១១- លោក **សុខ សារាឧត្តម** | ប្រធាននាយកដ្ឋានថវិកា | សមាជិក |
| ១២- លោក **ស៊ឹម អៀង** | ប្រធាននាយកដ្ឋានពន្ធដារ | សមាជិក |
| ១៣- លោក **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ | សមាជិក |
| ១៤- លោក **អូន ម៉ុនហាក់** | ប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ១៥- លោក **ម៉ី ម៉ាន់** | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ១៦- លោក **នេត មុន្នី** | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |

១៧- លោក ឈឹម សារ៉េត ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ សមាជិក

១៨- លោក ខា ធុនធរ៉ា ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង សមាជិក

១៩- លោក រស់ សីលវ៉ា ប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ សមាជិក

២០- លោក លឹម ម៉ិនហៃ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន សមាជិក

២១- លោក ឯក ធីរៈវឌ្ឍ អគ្គាធិការនៃអគ្គាធិការដ្ឋាន សមាជិក

២២- លោក សេង ស្រេង នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

២៣- លោក ម៉ោក សុធារិន ប្រធាននាយកដ្ឋានបុគ្គលិក សមាជិក

២៤- លោក ឃុត សាខន ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ សមាជិក

២៥- លោក អ៊ុយ សម្បត្តិ ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិង អាស៊ាន សមាជិក

២៦- លោក យ៉ិនន៍ តំរយឃន់ ប្រធាននាយកដ្ឋាននីតិកម្ម សមាជិក

២៧- លោក ផាន់ ផល្លា ប្រធានអង្គភាពពតិមានវិទ្យា សមាជិក

២៨- លោក អ៊ិន សុម៉េត ប្រធានអង្គភាពគ្រប់គ្រងសាច់ប្រាក់ សមាជិក

**ប្រការ ២.-**

ពាក្យ « គណៈកម្មាធិការការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» ដែលត្រូវបានប្រើនៅក្នុងប្រកាសលេខ ២១៨ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ត្រូវជំនួសដោយពាក្យ «គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» ហៅកាត់ «គកហ»។

**ប្រការ ៣ .-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៨

**គាត ឈន់**

**__ចំលងជូនៈ__**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាមីខ្លួន ដើម្បីអនុវត្ត
- កាលប្បវត្តិ ឯកសារ